

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតរំលែកមរណទុក្ខ

## ផ្ញើជូន

## ឯកឧត្តម ប្រាជ្ញ សារ៉ាត ព្រមទាំងក្រុមគ្រួសារ

ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អាន!

ខ្ញុំ និងភរិយា ពិតជាមានសេចក្តីក្តុកក្តួល ខ្វល់តក់ស្លុត និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា លោកជំទាវ នាយឧត្តមសេនីយ៍ **ម៉ី មនដារី** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ ដែលត្រូវជាភរិយាឯកឧត្តម បានទទួលមរណភាពនៅថ្ងៃពុធ ៥កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង០៨:២៥នាទី ក្នុងជន្មាយុ៦៩ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់លោកជំទាវ នាយឧត្តមសេនីយ៍ **ម៉ី មនដារី** មិនត្រឹមតែជាការបាត់បង់នូវភរិយា ម្តាយ ម្តាយក្មេក ជីដូន ជាទីគោរពស្រលាញ់ដ៏ជ្រាលជ្រៅ និងប្រកបដោយព្រហ្មវិហារធម៌ដ៏ខ្ពង់ខ្ពស់ចំពោះក្រុមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបាត់បង់ឥស្សរជនឆ្នើមមួយរូបនៃកងយោធពលខេមរភូមិន្ទ ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងប្រកបដោយឆន្ទៈមនសិការដ៏មោះមុត ក្នុងបុព្វហេតុបម្រើ **ជាតិ សាសនា ព្រះមហាក្សត្រ** និងបានការពារបូរណភាពទឹកដីជារៀងរហូតមក។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំ និងភរិយា សូមចូលរួមរំលែកមរណទុក្ខជាមួយក្រុមគ្រួសារ និងសាច់ញាតិនៃសព ដោយសេចក្តីអាឡោះអាល័យក្រអឺប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ដ៏ធំធេងនេះ។ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់លោកជំទាវ នាយឧត្តមសេនីយ៍ **ម៉ី មនដារី** សូមបានដល់ឋានបរមសុខ និងទាប់បានយានយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម ប្រាជ្ញ សារ៉ាត ព្រមទាំងក្រុមគ្រួសារ ទទួលនូវការស្រលាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ និងភរិយា។

ថ្ងៃពុធ ៥កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**